THE SCHOOL DISTRICT OF PHILADELPHIA

# សំណួរដែលគេឧស្សាហ៍សួរសម្រាប់ថ្នាក់មុនមត្តេយ្យ

## ការិយាល័យអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរ | ចម្លើយ |
|---|---|
| តើអស់ថ្លៃប៉ុន្មាន? | ឥតគិតថ្លៃទេ។ |
| តើនៅថ្ងៃណា និងម៉ោងប៉ុន្មាន? | ថ្នាក់មុនមត្តេយ្យ គឺជាកម្មវិធី ពីខែកញ្ញា ដល់ ខែមិថុនា ធ្វើតាមប្រតិទិនរបស់ក្រសួងអប់រំ។ ម៉ោងខុសៗគ្នាទៅតាមទីកន្លែង ប៉ុន្តែម៉ោងទូទៅគឺ៖<br>ថ្ងៃច័ន្ទ ដល់ ព្រហស្បតិ៍ ម៉ោង 8:30 ព្រឹក ដល់ 3:00 រសៀល<br>ថ្ងៃសុក្រ ម៉ោង 8:30 ព្រឹក ដល់ 12:30 រសៀល |
| តើកូនខ្ញុំនឹងទទួលអាហារថ្ងៃត្រង់ដែរឬទេ? | អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងអាហារសម្រន់ពេលរសៀល នឹងផ្តល់ឱ្យកូនលោកអ្នកដោយឥតគិតថ្លៃ។ សេវាកម្មនេះផ្តល់ឱ្យដោយកម្មវិធីចំណីអាហារសម្រាប់កុមារ និងមនុស្សពេញវ័យ (CACFP)។ |
| តើមានសេវាកម្មថយន្តសាលាដែរឬទេ? | ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា មិនផ្តល់សេវាកម្មដឹកជញ្ជូនក្មេងថ្នាក់មុនមត្តេយ្យទេ។ |
| តើខ្ញុំនឹងអាចជួបគ្រូរបស់កូនខ្ញុំ ហើយមើលថ្នាក់រៀនរបស់គាត់មុនថ្ងៃចូលរៀនដំបូងបានដែរឬទេ? | បាន មាតាបិតារបស់ក្មេងដែលទើបនឹងចុះឈ្មោះចូលរៀនថ្មីនឹងមានឱកាសនេះក្នុងអំឡុងពេលជួបប្រជុំណែនាំដែលបានកំណត់ពេលវេលារវាងមាតាបិតា និងគ្រូ។ |
| តើមាតាបិតាត្រូវបំពេញលិខិតដាក់ពាក្យសុំចូលរៀនថ្នាក់មុនមត្តេយ្យថ្មីដែរឬទេ ប្រសិនបើក្មេងត្រឡប់មកកម្មវិធីនេះវិញសម្រាប់ឆ្នាំទី ២? | មាតាបិតាភាគច្រើនមិនចាំបាច់បំពេញលិខិតដាក់ពាក្យសុំថ្មីទេ។ ទោះជាយ៉ាងណាក៏ដោយ គេអាចត្រូវការឯកសារថ្មីៗ។ |
| តើក្មេងថ្នាក់មុនមត្តេយ្យត្រូវមានអាយុប៉ុន្មាន? | ក្មេងត្រូវមានអាយុយ៉ាងតិច ៣ ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃទី១ ខែកញ្ញា នៃឆ្នាំដែលពួកគេចង់ចុះឈ្មោះចូលរៀនថ្នាក់មុនមត្តេយ្យ។<br>ប្រសិនបើក្មេងមានអាយុ ៥ ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃទី១ ខែកញ្ញា ពួកគេត្រូវតែចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ។ ប្រសិនបើក្មេងមានអាយុ ៥ ឆ្នាំ នៅថ្ងៃ ឬក្រោយថ្ងៃទី២ ខែកញ្ញា ពួកគេមានអាយុសមស្របសម្រាប់ថ្នាក់មុនមត្តេយ្យ។ |

THE SCHOOL DISTRICT OF PHILADELPHIA

# សំណួរដែលគេឧស្សាហ៍សួរសម្រាប់ថ្នាក់មុនមត្តេយ្យ

## ការិយាល័យអប់រំកុមារមុនថ្នាក់មត្តេយ្យ

| សំណួរ | ចម្លើយ |
| --- | --- |
| តើត្រូវការឯកសណ្ឋានដែរឬទេ? | ឯកសណ្ឋានមិនមែនជាតម្រូវការចាំបាច់សម្រាប់សិស្សថ្នាក់មុនមត្តេយ្យទេ។ ទោះជាយ៉ាងណាក៏ដោយ នាយកសាលាខ្លះតម្រូវឱ្យក្មេងថ្នាក់មុនមត្តេយ្យពាក់ឯកសណ្ឋានតាមពណ៌របស់សាលា។ ព័ត៌មានអំពីឯកសណ្ឋាននឹងពិភាក្សានៅក្នុងអង្គប្រជុំណែនាំមាតាបិតា។ |
| តើពេលណាទើបខ្ញុំដឹងថាតើកូនរបស់ខ្ញុំត្រូវបានទទួលឱ្យចូលរួមក្នុងកម្មវិធី? | គេនឹងជម្រាបទៅលោកអ្នកតាមការផ្ញើសំបុត្រ តាមការហៅទូរស័ព្ទ ឬតាមអ៊ីមែល អំពីការយល់ព្រមទទួលកូនលោកអ្នក ឬការដាក់ក្នុងបញ្ជីរង់ចាំក្នុងរយៈពេល ៦ សប្តាហ៍ នៃការបញ្ជូនលិខិតដាក់ពាក្យស្នើសុំរបស់កូនលោកអ្នក។ ការជូនដំណឹងអាចពន្យារពេលអាស្រ័យលើពេលវេលាក្នុងឆ្នាំដែលលោកអ្នកបានបញ្ជូនលិខិតដាក់ពាក្យស្នើសុំរបស់លោកអ្នក។ |
| ហេតុអ្វីបានជាកូនខ្ញុំត្រូវដាក់នៅក្នុងបញ្ជីរង់ចាំ ហើយតើកូនខ្ញុំអាចដាក់នៅក្នុងបញ្ជីរង់ចាំយូរប៉ុណ្ណា? | កន្លែងនីមួយៗមានកម្រិតប្រាក់ឧបត្ថម្ភ។ បញ្ជីរង់ចាំត្រូវបង្កើតឡើងនៅពេលចំនួននៃការដាក់ពាក្យស្នើសុំលើសកម្រិត។ ក្មេងក៏អាចត្រូវគេដាក់នៅក្នុងបញ្ជីរង់ចាំបន្តពេញឆ្នាំសិក្សា។ ការទទួលក្មេងពីបញ្ជីឈ្មោះរង់ចាំឱ្យចូលរៀននៅថ្នាក់មុនមត្តេយ្យគឺយោងទៅលើការចាកចេញរបស់ក្មេងផ្សេងទៀតពីកម្មវិធីមុនថ្នាក់មត្តេយ្យ ពីកន្លែងណាមួយ។ នៅពេលណាមានកន្លែងទំនេរ គេនឹងទាក់ទងទៅក្រុមគ្រួសារដែលមានឈ្មោះនៅក្នុងបញ្ជីរង់ចាំនៅទីតាំងនោះ។ |
| តើតម្រូវការនៃសិទ្ធិចូលរួមមានអ្វីខ្លះ? | -ជាអ្នករស់នៅក្នុងទីក្រុងហ្វីឡាដេលហ្វ្យ៉ា<br>-អាយុ (សូមមើលខាងលើ)<br>-ប្រាក់ចំណូលរបស់ក្រុមគ្រួសារ<br>(កម្រិតប្រាក់ចំណូល កំណត់តាមកម្រិតក្រីក្ររបស់សហព័ន្ធ ដែលចេញរាល់ខែមករា នៅក្នុងបញ្ជីសហព័ន្ធ ដោយក្រសួងមនុស្សធម៌ (DEPARTMENT OF HUMAN SERVICES) ហើយមានតាមអ៊ិនធ័រណិត នៅគេហទំព័រ WWW.HHS.GOV។) |